ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង៦:៣០នាទី មានសត្វផ្សោតឈ្មោល០១ក្បាល បានស្លាប់នៅកន្លែងអភិរក្សសត្វផ្សោតកោះកូនសត្វ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ តាមការពិនិត្យ និងវាយតម្លៃដោយមន្ត្រីជំនាញ នៃរដ្ឋបាលជលផល និងអង្គការ WWF សត្វផ្សោតស្លាប់នេះ មានលេខសម្គាល់០៥៦ ទម្ងន់១៦០គីឡូក្រាម ប្រវែង២,៣៨ម៉ែត្រ មានអាយុប្រមាណ២០ឆ្នាំ ដែលស្លាប់ដោយឧបករណ៍នេសាទ មង ដោយមានស្នាមរយៈនៅផ្នែកពោះ ស្នាមជាប់មងនៅគល់កន្ទុយ និងព្រុយចំហៀង គឺជាសត្វផ្សោតទី០១ ដែលស្លាប់ក្នុងឆ្នាំ២០២៣ នេះ។

សត្វផ្សោតទន្លេមេគង្គ គឺជារតនៈសម្បត្តិធម្មជាតិមានជីវិត ដែលមានប្រមាណ៩០ក្បាល រស់នៅតាមបណ្តោយដងទន្លេមេគង្គ នៃខេត្តក្រចេះនិងស្ទឹងត្រែង។ សត្វផ្សោតពេញវ័យអាចបន្តពូជបាន មានអាយុចាប់ពី៧ឆ្នាំ ហើយមានកូនក្នុងរយៈពេល២ឆ្នាំម្តង។ បច្ចុប្បន្ន សត្វផ្សោតរងការគំរាមកំហែង ដោយឧបករណ៍នេសាទ មង សន្ទូចរនង និងឧបករណ៍នក់។ ដូច្នេះ ទើបរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៤៧អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយកំណត់កន្លែងការពារនិងអភិរក្សសត្វផ្សោតប្រវែង១២០គីឡូម៉ែត្រ ចាប់ពីប៉ែកក្រោមស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រែង ខេត្តស្ទឹងត្រែង រហូតដល់ក្បាលកោះទ្រង់ ក្នុងខេត្តក្រចេះ ដោយហាមឃាត់ការធ្វើនេសាទ ដែលប្រើឧបករណ៍ មង សន្ទូចរនង និងឧបករណ៍នេសាទខុសច្បាប់ផ្សេងទៀត។ ទន្ទឹមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានសហការជាមួយរដ្ឋបាលខេត្តក្រចេះ និងស្ទឹងត្រែង ព្រមទាំងអង្គការដៃគូពាក់ព័ន្ធ បាននិងកំពុងបន្តពង្រឹងការការពារជាប្រចាំ នៅតំបន់ដែលសត្វផ្សោតរស់នៅ ក៏ដូចជាការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងតំបន់អំពីតម្លៃជាសកលដែលមិនអាចកាត់ថ្លៃបាន នៃសត្វផ្សោតទន្លេមេគង្គនេះ ដើម្បីរួមចំណែកធានានិរន្តរភាពនៃសត្វផ្សោតទន្លេមេគង្គ និងធនធានជលផលក្នុងធម្មជាតិ។ ទោះយ៉ាងនេះក្តី ការលួចដាក់មងនៅតែអាចកើតមាន ហើយដែលបង្កជាគ្រោះថ្នាក់ដូចករណីថ្ងៃនេះ។

ចំពោះមុខនេះ រដ្ឋបាលជលផល បន្តសហការជាមួយរដ្ឋបាលខេត្តក្រចេះ ស្ទឹងត្រែង និងអង្គការ WWF ព្រមទាំងស្វែងរកដៃគូសហការផ្សេងទៀត ដើម្បីពង្រឹងការការពារឱ្យបានម៉ឺងម៉ាត់ថែមទៀត ដោយជ្រើសរើសឆ្មាំទន្លេបន្ថែម និងប្រមូលផ្តុំកម្លាំងយាមល្បាតជាប្រចាំ នៅក្នុងតំបន់គ្រប់គ្រងសត្វផ្សោត ដើម្បីទប់ស្កាត់ឱ្យបាននូវការប្រើប្រាស់មង និងសន្ទូចរនង ព្រមទាំងឧបករណ៍នេសាទមិនស្របច្បាប់ដទៃទៀត និងបង្កើនការអប់រំ ផ្សព្វផ្សាយ និងបន្តពិនិត្យពីជម្រើសមុខរបរផ្សេងៗ។

រដ្ឋបាលជលផលសូមអំពាវនាវដោយទទូចដល់បងប្អូនប្រជានេសាទនៅតំបន់នោះ មេត្តាឈប់ប្រើប្រាស់មង សន្ទូចរនង និងឧបករណ៍នេសាទមិនស្របច្បាប់ដទៃទៀត ក្នុងតំបន់សត្វផ្សោតរស់នៅជាបន្ទាន់ ដើម្បីធានានិរន្តរភាពសត្វផ្សោត និងត្រីមេពូជរបស់យើង សម្រាប់ការទាក់ទាញទេសចរណ៍ បង្កើនកេរ្តិ៍ឈ្មោះប្រជាជាតិយើង និងទុកសម្រាប់កូនចៅយើងជំនាន់ក្រោយៗបានស្គាល់និងថែរក្សាបន្ត។

ថ្ងៃអាទិត្យ ១៣រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣

អាសយដ្ឋានៈអាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ /Fax: (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O.Box 582 /Fax: (855) 23 215 470 www.fia.gov.kh

Scanned with CamScanner